

# គោល នយោបាយ ការពារកុមារ

កែសម្រួលជាថ្មីនៅខែមករាឆ្នាំ ២០២១

CAMBODIAN CHILDREN'S FUND

cambodianchildrensfund.org



# មាតិកា


## សេចក្ដីផ្ដើម

គោលការណ៍ណែនាំ ៤

## ដែនកំណត់

ការគ្រប់គ្រងតាក់តែងច្បាប់ ៥

## គោលនយោបាយ

គោលបំណងនៃគោលនយោបាយ ៦

គោលការណ៍ណែនាំ ៧

និយមន័យ ៨

## ការការពារកុមារ & ការគ្រប់គ្រងហានិភ័យ

ការយល់ដឹង ១០

នីតិវិធីជ្រើសរើសបុគ្គលិក ១០

ការបណ្ដុះបណ្ដាល ១១

ការប្រព្រឹត្ត ១១

ការទំនាក់ទំនង & ការប្រើប្រាស់រូបភាពរបស់កុមារ ១២

ការឧបត្ថម្ភ និង ការណែនាំ ១២

ការរាយការណ៍ និង ការឆ្លើយតប ១៣

## ឧបសម្ព័ន្ធក១: ក្រមសីលធម៌ការពារកុមារ ១៤

(បុគ្គលិក អ្នកជាប់កិច្ចសន្យា អ្នកប្រឹក្សាយោបល់ និងអ្នកស្ម័គ្រចិត្ត)

## ឧបសម្ព័ន្ធក២: ក្រមសីលធម៌ការពារកុមារ (ភ្ញៀវ) ១៧

## ឧបសម្ព័ន្ធខ: ដំណើរការរាយការណ៍ពីការការពារកុមាររបស់ស៊ីស៊ីអេហ្វ ២០


---

### សេចក្ដីប្រកាសបដិសេធមិនទទួលខុសត្រូវចំពោះមុខច្បាប់

ប្រភពទិន្នន័យរបាយការណ៍ និងព័ត៌មាននេះដកស្រង់ចេញពីអង្គការក្នុង និងក្រៅរដ្ឋាភិបាល។ រូបភាពនៅក្នុងឯកសារនេះត្រូវបានថតដោយចៃដន្យ។ រូបភាពទាំងនេះមិនត្រូវបានបង្ហាញពីការឈឺចាប់ ជួញដូរ ឬរំលោភបំពានកុមារនោះទេ។

# សេចក្តីផ្តើម

អង្គការមូលនិធិកុមារកម្ពុជា (ស៊ីស៊ីអេហ្វ) ធ្វើការជាមួយសហគមន៍ក្រីក្រមួយចំនួនក្នុងប្រទេសកម្ពុជា។ ស៊ីស៊ីអេហ្វ ផ្តល់ការអប់រំ អាហារូបត្ថម្ភ ការព្យាបាលដល់កុមារដែលងាយរងគ្រោះដើម្បីផ្លាស់ប្តូរជីវិតថ្មីសំរាប់ពួកគេ។ សព្វថ្ងៃស៊ីស៊ីអេហ្វ ផ្តល់ការមើលថែកុមារជាង២០០០នាក់ នឹងបន្តផ្តល់សេវារបស់ខ្លួនបន្ថែមទៀតដល់គ្រួសារ និង សហគមន៍កំពុងជួបប្រទះវិបត្តិ។

អង្គការមូលនិធិកុមារកម្ពុជា ប្តេជ្ញាចិត្តបង្កើតគោលនយោបាយការពាកុមារក្នុង គោលបំណងដើម្បីការពារកុមារពីការរំលោភបំពាន និងមិនលើកលែងទោសចំពោះការរំលោភបំពាន ព្រមទាំងរូបភាពអាសអាភាសរបស់កុមារ។ ស៊ីស៊ីអេហ្វ កំណត់រាល់វិធានការចាំបាច់ដែលមានសក្តានុពលដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យការរំលោភបំពានលើកុមារ ឬមនុស្សវ័យក្មេងនៅក្នុងកម្មវិធីអង្គការអោយទទួលបានការមើលថែ និងការពារពួកគេពីគ្រោះថ្នាក់។

ស៊ីស៊ីអេហ្វ ទទួលខុសត្រូវចំពោះកាតព្វកិច្ច និងប្តេជ្ញាចិត្តយ៉ាងខ្ជាប់ដើម្បីធានាថាយើងនៅតែបន្តផ្តល់ សុវត្ថិភាព អាហារូបត្ថម្ភ និងបរិស្ថានសប្បាយរីករាយដល់ក្មេងៗឬសិស្សានុសិស្សដែលយើងមើលថែ។

ស៊ីស៊ីអេហ្វទទួលស្គាល់ថាបុគ្គលិក ដែលធ្វើការជិតស្និទ្ធជាមួយកុមារទោះជាស្ថិតក្នុងមុខតំណែងណាមួយដែលមានឥទ្ធិពលឬអំណាចមកលើកុមារតម្រូវអោយធ្វើការយ៉ាងយកចិត្តទុកដាក់បំផុតចំពោះតួនាទីរបស់ខ្លួនដើម្បីទប់ស្កាត់ការរំលោភបំពានគ្រប់ទំរង់ណាមួយមកលើកុមារ ។

អង្គការមូលនិធិកុមារកម្ពុជា(ស៊ីស៊ីអេហ្វ) និងអ្នកជាប់ពាក់ព័ន្ធជាមួយស៊ីស៊ីអេហ្វត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារសុខុមាលភាពដល់កុមារទាំងអស់ដែលខ្លួនមើលថែទាំដោយយកចិត្តទុកដាក់បំផុតដោយគ្មានការលើកលែង។ គោលនយោបាយនេះបង្ហាញពីការប្តេជ្ញាចិត្តរបស់យើងក្នុងការផ្តល់អោយកុមារលើការរស់នៅ ឬសិក្សានៅតាមសាខារបស់ស៊ីស៊ីអេហ្វទាំងអស់អោយបានចូលរួមសកម្មភាពជាមួយស៊ីស៊ីអេហ្វប្រកបដោយបរិយាកាសសុវត្ថិភាពបំផុត។ ដូច្នេះយើងតម្រូវអោយមានការគ្រប់គ្រងសកម្មភាពដើម្បីទប់ស្កាត់ពីការរំលោភបំពានដោយចេតនា ឬអចេតនា និងការបង្កគ្រោះថ្នាក់គ្រប់ប្រភេទដល់កុមារ។ គោលនយោបាយនេះត្រូវបានអនុម័ត និងគាំទ្រទាំងស្រុងដោយគណៈគ្រប់គ្រង និងក្រុមការងារប្រតិបត្តិរបស់ស៊ីស៊ីអេហ្វ។

គោលបំណងរួមរបស់គោលនយោបាយការពារគឺៈ

*ប្រសិទ្ធភាពនៃការការពារកុមារពីគ្រប់ទំរង់នៃការរំលោភបំពានលើកុមារគឺស្ថិតក្រោមការយកចិត្ត ទុក្ខដាក់របស់អង្គការមូលនិធិកុមារកម្ពុជា។*




## គោលការណ៍ណែនាំ

**គោលការណ៍ណែនាំរបស់គោលនយោបាយការពារកុមារស៊ីស៊ីអេហ្វមាន៤ធំៗ**

- **មិនលើកលែងទោសចំពោះការរំលោភបំពានលើកុមារ**
- **ផលប្រយោជន៍របស់កុមារជាចម្បង**
- **ការទទួលខុសត្រូវផ្ទាល់ខ្លួន និងការទទួលខុសត្រូវរួមក្នុងការការពារកុមារ**
- **យុទ្ធសាស្រ្តដ៏សកម្មក្នុងការគ្រប់គ្រងហានិភ័យ**

# ដែនកំណត់

### ដែនអនុវត្តគោលនយោបាយការពារកុមារ

អង្គភាពរបស់ស៊ីស៊ីអេហ្វទាំងអស់រួមបញ្ចូលទាំងអង្គការមូលនិធិកុមារកម្ពុជានៅសហរដ្ឋអាមេរិច និងកម្ពុជា អង្គការមូលនិធិកុមារកម្ពុជានៅអូស្ត្រាលី អង្គការមូលនិធិកុមារកម្ពុជានៅហុងកុង និងអង្គការមូលនិធិកុមារកម្ពុជានៅចក្រភពអង់គ្លេស។

- **អង្គការនានា**
- **បុគ្គលិក (ទទួលបាន និងមិនទទួលបានប្រាក់កម្រៃ)**
- **អ្នកជាប់កិច្ចសន្យា អ្នកផ្តល់ប្រឹក្សាយោបល់ អ្នកស្ម័គ្រចិត្ត ភ្ញៀវ ម្ចាស់ជំនួយ អ្នកគាំទ្រ និងភ្នាក់ងារដៃគូណាមួយ។**

ស៊ីស៊ីអេហ្វ រំពឹងថាអង្គការនានា និយោជិក(ទទួលបានប្រាក់កម្រៃ និងមិនទទួលបានប្រាក់កម្រៃ)អ្នកម៉ៅការអ្នកប្រឹក្សាយោបល់ អ្នកស្ម័គ្រចិត្ត និងភ្នាក់ងារដៃគូចូលរួមអនុវត្តយ៉ាងសកម្មជាមួយគោលការណ៍ដែលរៀបរាប់យ៉ាងលម្អិតក្នុងគោលនយោបាយនេះ។ សម្រាប់គោលបំណងនៃគោលនយោបាយនេះ ពាក្យថា **"កុមារ"** មានន័យដល់មនុស្សដែលមានអាយុក្រោម១៨ឆ្នាំ និងស្ថិតនៅក្រោមការមើលថែរបស់ស៊ីស៊ីអេហ្វ។




## ការគ្រប់គ្រងតាក់តែងច្បាប់

គោលនយោបាយការពារកុមាររបស់ស៊ីស៊ីអេហ្វអនុវត្តតាមច្បាប់អន្តរជាតិស្តីពីការការពារ

- អនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (កម្ពុជាអនុម័តនៅឆ្នាំ ១៩៩២)
- ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ (កម្ពុជា)
- ច្បាប់ស្តីពីការគាំពារ និងព្យាបាលកុមារពីការរំលោភបំពាន ឆ្នាំ១៩៧៤ (សហរដ្ឋអាមេរិច)
- ច្បាប់គ្រួសារឆ្នាំ ១៩៧៥ (Commonwealth) (អូស្ត្រាលី)
- ច្បាប់កុមារឆ្នាំ ១៩៨៩ (ចក្រភពអង់គ្លេស)

# គោលនយោបាយ

## គោលបំណងនៃគោលនយោបាយ

គោលនយោបាយការពារកុមារ ត្រូវបានបង្កើតឡើងសំរាប់ផ្តល់ការណែនាំលើការអនុវត្តដើម្បីទប់ស្កាត់ការរំលោភបំពានលើកុមារនៅតាមសាខា និងក្នុងកម្មវិធីទាំងអស់របស់ស៊ីស៊ីអេហ្វ។ គោលនយោបាយនេះបង្ហាញពីយុទ្ធសាស្រ្តនានាក្នុងការគ្រប់គ្រងហានិភ័យ នឹងត្រូវយកមកអនុវត្ត ដើម្បីកាត់បន្ថយហានិភ័យគ្រប់កំរិតរបស់កុមារដែលងាយរងគ្រោះ។ គោលការណ៍ស្តីពីការការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទនិងការបៀតបៀនផ្លូវភេទ (PSEAH) ត្រូវបានដាក់បញ្ចូលនៅក្នុងគោលនយោបាយនេះផងដែរ។ទទួលខុសត្រូវរួមក្នុងការការពារកុមារយុទ្ធសាស្រ្តដ៏សកម្មក្នុងការគ្រប់គ្រងហានិភ័យ



- គោលនយោបាយការពារកុមារនឹងបង្ហាញពីការប្តេជ្ញាចិត្តរបស់ស៊ីស៊ីអេហ្វដើម្បីការពារកុមារពីការរំលោភបំពាន និងគ្រោះថ្នាក់ផ្សេងៗ។
- គោលបំណងរបស់គោលនយោបាយការពារកុមារគឺផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិក និងអ្នកជាប់ពាក់ព័ន្ធទាំងអស់ពីការរំលោភបំពានកុមារ និងលើកកម្ពស់វប្បធម៌សុវត្ថិភាព និងកុមារមេត្រីដែលអ្នកទាំងអស់គ្នាប្តេជ្ញារក្សាសុវត្ថិភាពដល់កុមារ។
- គោលបំណងរបស់គោលនយោបាយការពារកុមារគឺដើម្បីបង្កើតបរិយាកាសបើកចំហនិងការយល់ដឹងដែលការព្រួយបារម្ភទាក់ទងទៅនឹងសុវត្ថិភាព និងសុខុមាលភាពរបស់កុមារត្រូវបានលើកយកមកពិភាក្សាដោះស្រាយ ប្រកបដោយយុត្តិធម៌ និងសមស្របព្រមទាំងសិទ្ធិទាំងអស់ត្រូវបានការពារ។
- លើសពីនេះទៀតគោលនយោបាយការពារកុមារនឹងផ្តល់ការណែនាំអំពីរបៀបឆ្លើយតបចំពោះការព្រួយបារម្ភ និងការចោទប្រកាន់ពីការរំលោភបំពានលើកុមារ។ គោលនយោបាយការពារកុមារផ្តល់ការណែនាំដល់បុគ្គលិក និង អ្នកជាប់ពាក់ព័ន្ធពីរបៀបធ្វើការងារប្រកបដោយការគោរព និងមានប្រសិទ្ធភាពជាមួយកុមារ។ ជាមួយគ្នានេះផងដែរគោលនយោបាយនេះនឹងផ្តល់ឱ្យអ្នកពាក់ព័ន្ធទាំងអស់រួមទាំងបុគ្គលិក និងអ្នកផ្សេងទៀតនូវបរិយាកាសការងារប្រកបដោយសុវត្ថិភាព។
- ស៊ីស៊ីអេហ្វមានកាតព្វកិច្ចគោរពតាមច្បាប់ព្រហ្មទណ្ឌការពារកុមារក្នុងស្រុក និងអន្តរជាតិ ដែលហាមឃាត់ពីការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារ។ ដោយរួមបញ្ចូលទាំងច្បាប់ក្នុងស្រុកដែលមាននៅក្នុងកម្មវិធីរបស់ស៊ីស៊ីអេហ្វ ច្បាប់អន្តរជាតិ និងអនុសញ្ញាទាក់ទងនឹងការរំលោភបំពានលើកុមារ ការកេងប្រវ័ញ្ចលើកុមារគ្រប់ទម្រង់ ដូចជាទេសចរណ៍ផ្លូវភេទលើកុមារ ការជួញដូរផ្លូវភេទកុមារ ពលកម្មកុមារ និងការរំលោភបំពានផ្លូវភេទកុមារ។

## គោលការណ៍ណែនាំ

គោលការណ៍ណែនាំគោលនយោបាយការពារកុមាររបស់ស៊ីស៊ីអេហ្វត្រូវបានពន្យល់ដូចខាងក្រោមៈ

**មិនលើកលែងទោសចំពោះការរំលោភបំពានលើកុមារ**

ស៊ីស៊ីអេហ្វនឹងមិនលើកលែងទោសចំពោះការរំលោភបំពានលើកុមារ។ ស៊ីស៊ីអេហ្វ នឹងចាត់យុទ្ធសាស្រ្តសកម្មក្នុងការគ្រប់គ្រងហានិភ័យ ហើយធានាថាបុគ្គលិកដែលខ្លួនបានជ្រើសរើសឆ្លងកាត់វគ្គបណ្តុះបណ្តាល និងអនុវត្តភារកិច្ចស្របតាមគោលការណ៍ណែនាំ។ ស៊ីស៊ីអេហ្វ នឹងមិនជួលបុគ្គលណា ឬប្រើប្រាស់សេវាពីបុគ្គលណាដែលមិនស្គាល់អត្តសញ្ញាណច្បាស់លាស់ ឬអាចបង្កជាហានិភ័យដល់កុមារឡើយ។

**ការទទួលខុសត្រូវផ្ទាល់ និងការទទួលខុសត្រូវរួមក្នុងការការពារកុមារ**

ស៊ីស៊ីអេហ្វទទួលស្គាល់ពីការទទួលខុសត្រូវចំពោះផ្លូវច្បាប់ និងសីលធម៌របស់ខ្លួនហើយការការពារកុមារគឺជាទំនួលខុសត្រូវរបស់យើងទាំងអស់គ្នា។ ការការពារកុមារ គឺជាទំនួលខុសត្រូវរបស់បុគ្គលិកគ្រប់ផ្នែកទាំងអស់ដែលទាមទារអោយមានការសហការ និង ចូលរួមយ៉ាងសកម្មពីបណ្តាអង្គការនានាដែលជាប់ពាក់ព័ន្ធជាមួយស៊ីស៊ីអេហ្វរួមមានៈ

បុគ្គលិក អង្គការនានា បុគ្គលិក (ទទួលបាន និងមិនទទួលបានប្រាក់កម្រៃ) អ្នកជាប់កិច្ចសន្យា អ្នកប្រឹក្សាយោបល់ អ្នកស្ម័គ្រចិត្ត ភ្ញៀវ ម្ចាស់ជំនួយ និងភ្នាក់ងារដៃគូនានា។ល។

**យុទ្ធសាស្រ្តសកម្មក្នុងការគ្រប់គ្រងហានិភ័យ**

ស៊ីស៊ីអេហ្វ ជឿជាក់ថាគ្រប់កម្មវិធីទាំងអស់របស់ស៊ីស៊ីអេហ្វមាននីតិវិធីក្នុងការគ្រប់គ្រងវាយតម្លៃហានិភ័យដូចខាងក្រោម៖

- កម្មវិធីទាំងអស់ត្រូវបានវាយតម្លៃពីហានិភ័យ
- ការត្រួតពិនិត្យ និងតាមដានជាប្រចាំដើម្បីកំណត់ពីហានិភ័យដែលអាចកើតមានឡើង
- ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធគ្រប់កម្មវិធីទាំងអស់ក្នុងការដោះស្រាយបញ្ហា
- ត្រូវប្រាកដថា ហានិភ័យត្រូវបានកំណត់គ្រប់គ្រង និងចាត់តាំងបុគ្គលិកក្នុងការទទួលខុសត្រូវ

# និយមន័យ



**កុមារ ឬមនុស្សវ័យក្មេង:** គឺសំដៅលើមនុស្សដែលមានអាយុក្រោម១៨ឆ្នាំ ហើយទទួលស្គាល់ដោយច្បាប់របស់ប្រទេស ពីភាពដែលមិនទាន់ពេញវ័យ។ គោលបំណងគោលនយោបាយការពារកុមារ របស់អង្គការមូលនិធិកុមារកម្ពុជា (ស៊ីស៊ីអេហ្វ) ទទួលស្គាល់ ថាកុមារគឺជាមនុស្សដែលមានអាយុក្រោម១៨ឆ្នាំ។

**ការការពារកុមារ:** គឺជាពាក្យត្រូវបានគេប្រើសំរាប់ រៀបរាប់ពីទំនួលខុសត្រូវ និងសកម្មភាពនានាធ្វើឡើងដើម្បីទប់ស្កាត់ ឬបញ្ឈប់ការរំលោភបំពាន និងធ្វើបាបកុមារ។

**ការរំលោភបំពានកុមារ:** កើតឡើងលើកុមារគ្រប់អាយុមិនថា ភេទប្រុស ភេទស្រី ជាតិសាសន៍ ប្រវត្តិសង្គម សមត្ថភាព ទំនោរផ្លូវភេទ ជំនឿសាសនា និងការញុះញង់ផ្នែកនយោបាយ។ ការរំលោភបំពានលើកុមារ ត្រូវបានបែងចែកជាការរំលោភពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត ការបោះបង់ឬព្រងើយកន្តើយ ការសម្លុតពលកម្មកុមារ និងអំពើហិង្សាក្នុងគ្រួសារ។

**កាតព្វកិច្ចថៃទាំ:** តាមច្បាប់ទូទៅសំដៅដល់ការទទួលខុសត្រូវរបស់អង្គការក្នុងការការពារកុមារ អោយបានល្អពី  កំរិតនៃគ្រោះថ្នាក់នានា។  វាជាកាតព្វកិច្ចរបស់អង្គការដើម្បីការពារកុមារពីគ្រប់មូលហេតុនៃការរងរបួស ឬគ្រោះថ្នាក់ដែលអាចមើលឃើញ។

**ការរំលោភបំពានផ្លូវកាយ:** កើតឡើងនៅពេល នណាម្នាក់មានបំណងធ្វើអោយកុមារឬមនុស្សវ័យក្មេងរងរបួស ឬការគំរាមកំហែង។ សកម្មភាពនេះអាចរាប់បញ្ចូលទាំងទំរង់នៃ ការទះ មួលក្តិច ក្រវី ទាត់ធាក់ ដុត រុញ ចាប់។ ទម្រង់នៃការរំលោភបំពាននេះអាចបង្ករបួសស្នាម ដាច់ ហើយ រលាក និងបាក់ឆ្អឹងរបស់កុមារ។

**ការរំលោភបំពានផ្លូវចិត្ត:** សំដៅដល់ពេលដែលកុមារត្រូវបានបដិសេធច្រើនដង ឬ គំរាមកំហែង។ ទង្វើទាំងនេះរួមមានការហៅឈ្មោះ(ដាក់ងារ) កុមារត្រូវបានឪពុកម្តាយឬអ្នកមើលថែបន្ទោសបង្អាប់  ឬបន្តស្តីបន្ទោសដែលវាបង្កអោយមានផលប៉ះពាល់ដល់ការលូតលាស់រាងកាយ និងផ្លូវចិត្តរបស់កុមារ។

**ការមិនយកចិត្តទុកដាក់ ឬព្រងើយកន្តើយ:** សំដៅលើការខកខាន ឬបដិសេធដោយចេតនាក្នុងការផ្តល់ ទឹកស្អាត ចំណីអាហារ ទីជំរក ផ្នែកអនាម័យ ការមើលថៃ ការយកចិត្តទុកដាក់កុមារដែលបង្កជាហានិភ័ដល់សុខភាព និងការអភិវឌ្ឍរបស់កុមារ។

**ការរំលោភបំពានផ្លូវភេទ:** សំដៅលើកុមារ ឬមនុស្សវ័យក្មេងត្រូវបានមនុស្សចាស់ ឬមនុស្សពេញវ័យដែលមានអាយុច្រើនជាងប្រើប្រាស់ក្នុងគោលបំណងរំញោច ឬបំពេញនូវតម្រូវការផ្លូវភេទផ្ទាល់ខ្លួនជាមួយកុមារដោយ

ភាគច្រើនមិនគិតពីអាយុ ការព្រមព្រៀងជាមូលដ្ឋាន។ សកម្មភាពទាំងនេះ អាចកើតមានឡើងចំពោះកុមាររាប់បញ្ចូលទាំងការមានទំនាក់ទំនងជាមួយកុមារដោយផ្ទាល់ឬមិនផ្ទាល់ ការគំរាមកំហែង និងការដាក់តាំងបង្ហាញរូបអាសអាភាសអោយកុមារមើល។

**ទេសចរណ៍ផ្លូវភេទកុមារ:** តាមនិយមន័យបញ្ឈប់ពេស្យាចារកុមារ រូបអាសអាភាសកុមារ និងការជួញដូរកុមាររបស់(ECPAT) អន្តរជាតិបានកំណត់ថា ទេសចរណ៍ផ្លូវភេទកុមារសំដៅលើ "ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារដោយបុរស ឬស្ត្រីដែលធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ពីប្រទេសអភិវឌ្ឍមកកាន់ប្រទេសដែលមានការអភិវឌ្ឍតិចតួចក្នុងគោលបំណងទាក់ទងសកម្មភាពផ្លូវភេទជាមួយកុមារ ដែលមានអាយុក្រោម ១៨ ឆ្នាំ" (ECPAT International, 2006)។

**ការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSE):** គឺជាទម្រង់នៃការកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទលើកុមារ តាមរយៈប្រព័ន្ធអ៊ីនធឺណេតដែលរួមបញ្ចូលទាំងកម្មសិទ្ធិនៃការផលិត និងការចែកចាយ ការរំលោភបំពានផ្លូវភេទកុមារតាមរយៈសម្ភារៈនិយម(CSAM) អនឡាញ និងសក្តានុពលនៃការលួងលោមជនរងគ្រោះតាមរយៈការផ្សព្វផ្សាយបន្តផ្ទាល់ពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ(CSEA) ។

**ការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទកុមារ (CSEA):** សំដៅលើការបញ្ចូលអត្ថន័យពីររវាងការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទដែលធ្វើដោយមនុស្សពេញវ័យមកលើកុមារ។ ការកេងប្រវ័ញ្ចផ្លូវភេទទាក់ទងទៅនឹងទំនាក់ទំនងផ្លូវភេទជាមួយកុមារដោយមានសំណងជាប្រាក់ក្នុងការដោះដូរសេវាផ្លូវភេទ កុមារអាចទទួលបានត្រឹមតែអាហារ ឬកន្លែងសំរាប់គេង។ ការរំលោភបំពានផ្លូវភេទត្រូវបានយល់ថា ជាការទាក់ទងទៅនឹងកន្លែងឯកជនភាពរបស់កុមារដោយមានការយល់ព្រម ឬមិនយល់ព្រម និងដោយមាន ឬគ្មានការបង្ខិតបង្ខំលើរាងកាយរបស់កុមារ។ ការរំលោភបំពានមិនតម្រូវអោយមានធាតុផ្សំនៃការដោះដូរនោះទេ ហើយវាអាចកើតឡើងដោយការពេញចិត្តខាងផ្លូវភេទរបស់បុគ្គលដែលប្រព្រឹត្តអំពើនោះតែប៉ុណ្ណោះ។

**ការរំលោភបំពានផ្លូវភេទលើកុមារតាមរយៈសម្ភារ (CSAM):** ត្រូវបានទទួលស្គាល់ថាជា 'រូបអាសអាភាសរបស់កុមារ' ក្នុងអត្ថន័យនេះសំដៅលើសម្ភារៈទាំងឡាយណាដែលពណ៌នាអំពីទង្វើ រំលោភបំពានផ្លូវភេទ ឬផ្តោតលើប្រដាប់បន្តពូជរបស់កុមារ។ ដោយអនុលោមតាមគោលការណ៍ណែនាំវាក្យស័ព្ទអន្តរជាតិ ពាក្យ (CSAM) សំដៅលើ 'រូបអាសអាភាសកុមារ' ប្រើជំនួសវិញ។ ចំណាំ: តាមការតាក់តែងច្បាប់របស់កម្ពុជា បច្ចុប្បន្នបានកំណត់ថាការប្រើប្រាស់រូបភាពអាសអាភាសរបស់កុមារគឺជាបទល្មើស។

**ការលួងលោម:** ជាឈ្មោះខ្លីមួយដែលប្រើប្រាស់ក្នុងគោលបំណងស្នើសុំសេវាផ្លូវភេទពីមួយកុមារ។ នៅក្នុងបរិបទកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSE) សំដៅលើដំណើរការណ៍នៃការបង្កើត ឬកសាងទំនាក់ទំនងជាមួយកុមារដោយផ្ទាល់ ឬតាមរយៈប្រព័ន្ធអនឡាញឬតាមបច្ចេកវិទ្យាផ្សេងទៀតដើម្បីសម្រេចបាននូវទំនាក់ទំនងផ្លូវភេទតាមរយៈ អ៊ីនធឺណេត ឬក្រៅប្រព័ន្ធអ៊ីនធឺណេតជាមួយកុមារ។

**ការបៀតបៀន:** តាមគោលនយោបាយការពារកុមារពីការកេងប្រវ័ញ្ច និងបៀតបៀនផ្លូវភេទកុមាររបស់ស៊ីស៊ីអេហ្វបានកំណត់ថា ការបៀតបៀនត្រូវបានចាត់ទុកថាជា ការសម្លុតផ្ទាល់ ការជេរ ការប្រមាថ ការគំរាមកំហែងនិងការសើចចំអកអោយកុមារ។

**ការសម្លុត** គឺជាការប្រើប្រាស់អំណាចមិនសមរម្យពីបុគ្គល ឬក្រុមធ្វើឱ្យមានរបួសទាំងផ្លូវកាយ ឬផ្លូវចិត្ត ជាធម្មតាសកម្មភាពដែលកើតឡើងដោយចេតនា និងច្រើនដង។ ការសម្លុតអាចកើតឡើងលើផ្លូវកាយ ឬផ្លូវចិត្ត (ដោយពាក្យសំដី និងមិនដោយពាក្យសម្តី)

- ការសម្លុតដោយពាក្យសំដី រាប់បញ្ចូល ការជេរប្រមាថ ការគំរាមកំហែង និងការចំអក។
- ការសម្លុតដោយផ្លូវចិត្ត រាប់បញ្ចូល ការបំភិតបំភ័យផ្នែករាងកាយ និងការរើសអើង។
- ការសម្លុតឬធ្វើបាបលើផ្លូវកាយ រាប់បញ្ចូលទាំង ការរុញ វាយ ដាល់ ទាត់ ឬសកម្មភាពផ្សេងទៀតដែលបង្កអោយមានការឈឺចាប់ ឬរបួសស្នាម។

**រងផលប៉ះពាល់ទៅនឹងអំពើហិង្សាក្នុងគ្រួសារ**
អំពើហឹង្សាក្នុងគ្រួសារកើតឡើងនៅពេលកុមារ និងមនុស្សវ័យក្មេងស្ថិតក្នុងស្ថានភាពជាសាក្សី ឬធ្លាប់ជួបប្រទះការត្អូញត្អែរ៉ាំរ៉ៃ ការបង្ខិតបង្ខំ ការបំភិតបំភ័យ ជាជនរងគ្រោះត្រូវបានធ្វើបាបពីមនុស្សណាម្នាក់ និងមនុស្សផ្សេងទៀតទៅលើរាងកាយ ផ្លូវភេទ ឬផ្លូវអារម្មណ៍ដែលមានទំនាក់ទំនងស្និតស្នាលនឹងគ្នា (កែសម្រួលពីនិយមន័យសមាគមវេជ្ជសាស្ត្រអូស្ត្រាលី)។

**កុមារងាយរងគ្រោះ** ការរំលោភបំពានលើកុមារកើតឡើងមិនត្រឹមតែនៅក្នុងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែអាចកើតឡើងនៅខាងក្រៅគ្រួសារផងដែររួមមានៈ ស្ថាប័ន នៅកន្លែងធ្វើការ នៅតាមដងផ្លូវក្នុងតំបន់មានសង្គ្រាម និងកន្លែងដែលមានគ្រោះអាសន្ន។

# ការការពារកុមារ និង ការគ្រប់គ្រងហានិភ័យ

## ការការពារកុមារ និងការត្រួតពិនិត្យហានិភ័យ របស់ ស៊ីស៊ីអេហ្វ

ស៊ីស៊ីអេហ្វទទួលស្គាល់ថាមានកត្តាហានិភ័យដែលអាចកើតឡើងចំពោះកុមារតាមរយៈការផ្តល់កម្មវិធីរបស់យើងដល់ជនងាយរងគ្រោះ និងជួបការលំបាក។ ក្នុងការកំណត់ហានិភ័យទាំងនេះស៊ីស៊ីអេហ្វ ធ្វើការវាយតម្លៃយ៉ាងយកចិត្តទុកដាក់ និងគ្រប់គ្រងហានិភ័យទាំងនេះសំរាប់កុមារនៅក្នុងកម្មវិធីរបស់យើង (និងនៅក្នុងសហគមន៍ដែលយើងកំពុងធ្វើការជាមួយ)ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់។ ការងារនេះសម្រេចទៅបានដោយមានការពិនិត្យលើកម្មវិធី និមួយៗរបស់ខ្លួន និងផលប៉ះពាល់ដែលមានសក្តានុពលដល់កុមារ។ កម្មវិធីដែលពាក់ព័ន្ធនឹងការងារផ្ទាល់ជាមួយកុមារត្រូវបានចាត់ទុកថាមានហានិភ័យខ្ពស់ ដូច្នេះតម្រូវឱ្យមាននីតិវិធីការពារកុមារយ៉ាងតឹងរ៉ឹង។

ទោះជាយ៉ាងណាក៏ដោយ ដោយសារតែកុមារ គឺជាផ្នែកមួយនៃសហគមន៍ដែលយើងធ្វើការជាមួយ យើងតែងតែគិតគូរអំពីសក្តានុពលនៃហានិភ័យជានិច្ច។ ការគ្រប់គ្រងហានិភ័យគឺជាផ្នែកមួយនៃសកម្មភាពដែលបន្តធ្វើជារៀងរហូតហើយស៊ីស៊ីអេហ្វធ្វើការវាយតម្លៃហានិភ័យលើការការពារកុមារគ្រប់កម្មវិធី និងគម្រោងថ្មីៗទាំងអស់ រាប់បញ្ចូលទាំងការគ្រប់គ្រងកម្មវិធីគម្រោង។

បុគ្គលិក និងអ្នកជាប់ពាក់ព័ន្ធទាំងអស់បន្តយល់ដឹងអំពីហានិភ័យ ហើយត្រូវចូលរួមកាត់បន្ថយយ៉ាងសកម្មចំពោះឱកាស និងស្ថានភាពដែលអាចបង្កគ្រោះថ្នាក់ដល់កុមារ។

រាល់ការចោទប្រកាន់ណាមួយទាក់ទងទៅនឹងការរំលោភបំពានលើកុមារត្រូវរាយការណ៍ទៅ **safeguarding@cambodianchildrensfund.org** ។ ជម្រើសនៃការរាយការណ៍នឹងត្រូវបានកែសម្រួលកំឡុងពេលផ្តល់វគ្គបណ្តុះបណ្តាលប្រចាំឆ្នាំ។

## ការយល់ដឹង

អ្នកតំណាងទាំងអស់ត្រូវមានការទទួលខុសត្រូវផ្ទាល់ខ្លួន និងទទួលខុសត្រូវរួមក្នុងការការពារកុមារ ហើយត្រូវយល់ដឹងពីគោលនយោបាយ គោលការណ៍ណែនាំទាក់ទងទៅនឹងការប្រព្រឹត្ត ឬពិធីការពាក់ព័ន្ធនានា។ បុគ្គលិកដែលត្រូវបានចាត់តាំងអោយទទួលខុសត្រូវក្នុងការត្រួតពិនិត្យបញ្ហាការពារកុមារ នឹងជួយសម្របសម្រួលដល់ការអនុវត្តគោលនយោបាយ ផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិក និងលើកកម្ពស់ការយល់ដឹងពីដំណើរការរាយការណ៍ឧប្បត្តិហេតុ។

ព័ត៌មានដែលទាក់ទងទៅនឹងកុមារមេត្រីបង្កភាពងាយស្រួលសម្រាប់កុមារ គឺអាចស្វែងរកបានដើម្បីធានាថាកុមារយល់អំពីសុវត្ថិភាព និងការការពារខ្លួនរបស់ពួកគេ និងគ្មានការបារម្ភនៅពេលនិយាយទៅកាន់នរណាម្នាក់នៅពេលពួកគេមានបញ្ហាណាមួយ។ កុមារនឹងត្រូវបានណែនាំឱ្យស្គាល់បុគ្គលិកឯករាជ្យណាម្នាក់ដែលខ្លួនអាចនិយាយទៅកាន់ ឬ រាយការណ៍បានប្រសិនបើពួកគេមានការព្រួយបារម្ភនានា។ កុមារនឹងត្រូវបានលើកទឹកចិត្តឱ្យនិយាយនៅពេលណាក៏បាននូវអ្វីដែលពួកគេអាចទទួលយកបាន និងមិនអាចទទួលយកបានតាមមធ្យោបាយដែលពួកគេត្រូវបានទាក់ទងដោយមនុស្សពេញវ័យឬមនុស្សវ័យក្មេងដទៃទៀត

## នីតិវិធីជ្រើសរើសបុគ្គលិក

នីតិវិធីសម្រាប់ជ្រើសរើសបុគ្គលិកបានចែងពីវិធានការការពារកុមារសមស្របរាប់បញ្ចូលទាំងការផ្តល់ព័ត៌មាន ប្រវត្តិរូបសង្ខេប និងឯកសារយោងពីគ្រប់ទីកន្លែងដែលអាចធ្វើទៅបាន។ ស៊ីស៊ីអេហ្វ នឹងធ្វើការបដិសេធមិនទទួលបុគ្គលណាដែលអាចបង្កហានិភ័យដល់សុវត្ថិភាពរបស់កុមារ។

ដើម្បីជាជំនួយដល់ដំណើរការត្រួតពិនិត្យ និងជ្រើសរើសបុគ្គលិក ស៊ីស៊ីអេហ្វតម្រូវឱ្យបុគ្គលិកក្នុងស្រុក និងក្រៅស្រុកទាំងអស់មានឯកសារបញ្ជាក់លិខិតថ្កោលទោស (ឬឯសារស្តង់ដាពាក់ព័ន្ធ)។ ឯកសារយោងត្រូវប្រគល់អោយ ហើយបុគ្គលិកផ្នែកសម្ភាសន៍នឹងធ្វើការទាក់ទងទៅអ្នកធានាដើម្បីបញ្ជាក់ពីអត្តចរិករបស់បេក្ខជនដែលដាក់ពាក្យស្នើសុំបំរើការងារ និងឯកសារដែលពិតជាត្រឹមត្រូវមែន។ ការវាយតម្លៃអាកប្បកិរិយារបស់បេក្ខជនទាំងអស់ដែលដាក់ពាក្យសុំមុខតំណែងដែលពាក់ព័ន្ធនឹងការធ្វើការជាមួយកុមារត្រូវធ្វើនៅពេលសម្ភាសន៍។ បុគ្គលិក អ្នកជាប់កិច្ចសន្យា និងអ្នកជាប់ពាក់ព័ន្ធទាំងអស់ត្រូវបង្ហាញភ្លាមៗនូវឯកសារពាក់ព័ន្ធរួមមានការចោទប្រកាន់ ការផ្តន្ទាទោស និងលទ្ធផលផ្សេងទៀតនៃបទល្មើសដែលបានកើតឡើងពីមុន ឬកើតឡើងក្នុងអំឡុងពេលទំនាក់ទំនងការងារជាមួយស៊ីស៊ីអេហ្វដែលទាក់ទងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារលើទម្រង់ណាមួយដូចបានរៀបរាប់លម្អិតនៅក្នុងគោលការណ៍នេះ។

បេក្ខជនដែលបានឆ្លងកាត់ការសម្ភាសន៍ដោយជោគជ័យទាំងអស់ និងមានអ្នកតំណាងទាក់ទងជូនដំណឹងពីតម្រូវការកិច្ចសន្យារបស់ពួកគេដោយអនុវត្តតាមគោលការណ៍នេះ ដោយមានការចុះហត្ថលេខា និងគោរពតាមក្រមសីលធម៌ការពារកុមាររបស់ស៊ីស៊ីអេហ្វមុនពេលចាប់ផ្តើមការងារជាមួយស៊ីស៊ីអេហ្វ។

## ការបណ្តុះបណ្តាល

បុគ្គលិករបស់ស៊ីស៊ីអេហ្វ ត្រូវទទួលវគ្គបណ្តុះបណ្តាលជាប្រចាំស្តីពី ការការពារកុមារដើម្បីជួយពួកគេអោយមានចំណេះដឹង បច្ចុប្បន្នភាពគោលនយោបាយ និងអនុវត្តគោលនយោបាយការពារកុមារបានល្អ ។ បុគ្គលិកស៊ីស៊ីអេហ្វទាំងអស់ត្រូវចូលរួមវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអ៊ីនធឺណិត/អនឡាញ ឬការចូលរួមវគ្គបណ្តុះបណ្តាលដោយផ្ទាល់ជារៀងរាល់ឆ្នាំ ដើម្បីធានាថាពួកគេមានសមត្ថភាពក្នុងការចាប់ផ្តើមរៀបចំពាក្យបណ្តឹង និងគ្រប់គ្រងវាដោយអនុវត្តតាមដំណើរការរាយការណ៍។

ប្រធានផ្នែកការការពារកុមារស្ថិតក្រោមការគ្រប់គ្រងដោយនាយកគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការមានតួនាទីក្នុងការផ្តល់ព័ត៌មានបច្ចុប្បន្នភាព និងការផ្លាស់ប្តូរថ្មីៗរបស់គោលនយោបាយការពារកុមារដល់បុគ្គលិក ផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិក និងកុមារទាំងអស់។

## ការប្រព្រឹត្ត

អ្នកតំណាងទាំងអស់តម្រូវឲ្យប្រកាន់អាកប្បកិរិយាសមរម្យ គោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់កុមារនៅពេលធ្វើការជាមួយកុមារ និងចូលរួមកាត់បន្ថយស្ថានភាពដែលអាចបង្កហានិភ័យដល់កុមារស្របតាមក្រមសីលធម៌ការពារកុមាររបស់ស៊ីស៊ីអេហ្វ(ឧបសម្ព័ន្ធ ក)។ អ្នកតំណាងទាំងអស់នឹងៈ

- គោរព និងយកចិត្តទុកដាក់ចំពោះកុមារទាំងអស់ដោយមិនគិតពីអាយុ ពូជសាសន៍ សាសនា ភេទ ពិការភាព ឬស្ថានភាពផ្សេងៗ
- មិនត្រូវប្រព្រឹត្តឥរិយាបថ ឬការប្រើពាក្យសំដីមិនសមរម្យដាក់កុមារដែលចាត់ទុកថាជាលក្ខណៈបៀតបៀន រំលោភបំពាន ញុះញង់ ឬបង្ខូចកេរ្តិ៍ឈ្មោះកុមារ។
- មិនត្រូវបញ្ចុះបញ្ចូលកុមារអោយចូលរួមទំរង់នៃសកម្មភាពផ្លូវភេទ ឬទង្វើណាមួយ រួមទាំងការបង់ប្រាក់សម្រាប់សេវាផ្លូវភេទ ឬសកម្មភាពដែលនៅក្រោមច្បាប់ពាក់ព័ន្ធទៅនឹងកុមារស្ថិតអាយុក្រោមការយល់ព្រម ឬទង្វើនោះជាបទល្មើស។
- នៅពេលធ្វើការជាមួយកុមារ ត្រូវប្រាកដថាមានវត្តមានមនុស្សពេញវ័យ(មិនត្រូវនៅកន្លែងស្ងាត់ ឬនៅតែពីរនាក់ជាមួយកុមារ)។
- មិនត្រូវនាំ ឬអញ្ជើញកុមារទៅផ្ទះរបស់ពួកគេ លុះត្រាតែពួកគេប្រឈមនឹងហានិភ័យភ្លាមៗក្នុងខណៈពេលនោះ។
- ចាត់វិធានការយ៉ាងធ្ងន់ធ្ងរចំពោះពាក្យបណ្តឹងនៃការរំលោភបំពានលើកុមារ ពីប្រភពណាមួយដែលដឹងថាជារបាយការណ៍ដែលប្រាសចាកពីក្រមសីលធម៌ការពារកុមារ ឬការព្រួយបារម្ភទាក់ទងទៅនឹងសុវត្ថិភាពកុមាររបស់ ស៊ីស៊ីអេហ្វ។
- ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ទំនាក់ទំនង ថតសម្លេង ឬប្រព័ន្ធផ្សព្វផ្សាយសង្គមសមរម្យដោយមិនទាញយកផលប្រយោជន៍ពីកុមារ មិនបៀតបៀន មិនដាក់កុមារចូលទៅក្នុងស្ថានភាពគ្រោះថ្នាក់ ឬគេហទំព័ររូបភាពអាសអាភាសរបស់កុមារដោយប្រើប្រាស់ឧបករណ៍ ឬ ប្រភពណាមួយ។
- មិនដាក់ទណ្ឌកម្មលើរាងកាយរបស់កុមារជាឧបករណ៍ក្នុងការដាក់ពិន័យដល់កុមារ។
- មិនទទួលកុមារអោយធ្វើការតាមផ្ទះ ឬការងារណាដែលមិនសមស្របតាមអាយុរបស់កុមារ ការអភិវឌ្ឍ ដែលរារាំងដល់ការអប់រំ ការកំសាន្ត និងដាក់ពួកគេក្នុងស្ថានភាពរងគ្រោះ។
- អនុវត្ត និងគោរពតាមច្បាប់ពាក់ព័ន្ធទាំងអស់។
- រាយការណ៍ពីការព្រួយបារម្ភ ឬការចោទប្រកាន់នានានៃការរំលោភបំពានលើកុមារកាន់តែឆាប់តាមដែលអាចធ្វើទៅបានតាមនិតិវិធីដែលបានកំណត់។
- ត្រូវប្រាកដថានៅពេលមានទំនាក់ទំនងជាមួយកុមារ ឬគ្រួសាររបស់កុមារស៊ីស៊ីអេហ្វ មិនអនុញ្ញាតអោយមនុស្សពេញវ័យ ឬបុគ្គលិកដែលមិនត្រូវបានតែងតាំងជាបុគ្គលិកពេញសិទ្ធិរបស់ស៊ីស៊ីអេហ្វអាចនាំកុមារចេញពីសាខារបស់ស៊ីស៊ីអេហ្វ ឬធ្វើទំនាក់ទំនងដោយឯករាជ្យជាមួយគ្រួសាររបស់កុមារនោះទេ។
- ស៊ីស៊ីអេហ្វ ជានិច្ចកាលតែងតែធានាថារាល់ព័ត៌មាន ឬរូបភាពដែលឆ្លុះបញ្ចាំងពីកុមារ មិនត្រូវបានប្រើប្រាស់ក្នុងមធ្យោបាយដែលធ្វើឲ្យកុមារប្រឈមនឹងហានិភ័យ ឬប៉ះពាល់ដល់សុវត្ថិភាព ឬសេចក្តីថ្លៃថ្នូររបស់ពួកគេនោះឡើយ។ បទប្បញ្ញត្តិគ្រប់គ្រងក្នុងការប្រើប្រាស់ការថតរូប និងវីដេអូរបស់កុមារបានចែងនៅក្នុងផ្នែកនៃ(ឧបសម្ព័ន្ធក)។

### ការទំនាក់ទំនង & ការប្រើប្រាស់រូបភាពកុមារ

ស៊ីស៊ីអេហ្វ នឹងផ្តល់ការគោរពដោយមានការព្រមព្រៀងត្រឹមត្រូវគ្រប់ពេលវេលាមុននឹងពណ៌នា និងប្រើប្រាស់រូបភាពរបស់កុមារ។

- កុមារត្រូវបានបង្ហាញក្នុងរូបភាពថ្លៃថ្នូរ និងប្រកបដោយការគោរពជានិច្ច ហើយមិនមែនពិពណ៌នាក្នុងលក្ខណៈដែលងាយរងគ្រោះ ឬគ្រប់គ្រងដោយនរណាម្នាក់ឡើយ។ កុមារត្រូវមានសម្លៀកបំពាក់សមរម្យ និងមិនត្រូវស្ថិតក្នុងឥរិយាបថដែលអាចមើលឃើញថាមានលក្ខណៈបង្ហាញបែបផ្លូវភេទឡើយ។
- កុមារ និងក្រុមគ្រួសារត្រូវបានស្នើសុំការយល់ព្រមជានិច្ច មុនពេលប្រើរូបភាពរបស់ពួកគេ។ នៅពេលស្នើសុំការយល់ព្រមក្នុងការប្រើប្រាស់រូបភាព ត្រូវប្រាប់កុមារ និងក្រុមគ្រួសារពីព័ត៌មានលម្អិតពីមធ្យោបាយ និងទីកន្លែងដែលរូបភាពនេះនឹងត្រូវបានប្រើប្រាស់។
- មិនត្រូវបង្ហាញព័ត៌មានដែលកំណត់អត្តសញ្ញាណរបស់កុមារនៅពេលបោះពុម្ពរូបភាពផ្សាយ ឬទីតាំងរបស់ពួកគេឡើយ។
- កុមារនឹងត្រូវបានពិពណ៌នា ឬបង្ហាញពីផ្នែកដែលមានក្នុងសហគមន៍របស់គេតែប៉ុណ្ណោះ។
- វប្បធម៌ ប្រពៃណី ក្នុងតំបន់ត្រូវបានវាយតម្លៃទាក់ទងនឹងការរឹតបណ្តឹងសម្រាប់ការផលិតរូបភាពផ្ទាល់ខ្លួនឡើងវិញ។
- រូបភាពគួរតែបង្ហាញអំពីភាពស្មោះត្រង់របស់បរិបទ និងភាពពិត។
- ពេលបញ្ជូនរូបភាព និងចំណងជើងឯកសារនានាតាមប្រព័ន្ធអេឡិចត្រូនិច ត្រូវប្រាកដថាវានឹងមិនបង្ហាញពីអត្តសញ្ញាណឡើយ។

ស៊ីស៊ីអេហ្វ នៅតែរក្សាទំនាក់ទំនងយ៉ាងរឹងមាំជាមួយឪពុកម្តាយរបស់កុមារ ឬអ្នកថែទាំកុមារស្របច្បាប់ ហើយធានាថា ពួកគេនឹងត្រូវបានផ្តល់ដំណឹងព័ត៌មានពីបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងកុមារ និងសុខមាលភាពរបស់ពួកគេ។

ស៊ីស៊ីអេហ្វ គោរព និងរក្សាព័ត៌មានសំងាត់ទាក់ទងទៅនឹងសុខភាព ប្រវត្តិគ្រួសារ និងប្រវត្តិផ្ទាល់ខ្លួនរបស់កុមារ។ មានតែបុគ្គលិកដែលត្រូវបានផ្តល់សិទ្ធិប៉ុណ្ណោះទើបអាចទទួលដឹងព័ត៌មានផ្ទាល់ខ្លួននេះបាន។

គោលការណ៍ណែនាំ វិន័យ  និងនីតិវិធីក្នុងការអនុវត្តការការពារកុមារមានសំរាប់បុគ្គលិករបស់ស៊ីស៊ីទាំងអស់។ មានតែបុគ្គលិកដែលមានសិទ្ធិ និងទទួលស្គាល់ពីថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់ស៊ីស៊ីអេហ្វប៉ុណ្ណោះទើបអាចមានសិទ្ធិក្នុងការផ្លាស់ប្តូរឬសំរេចិត្តទាក់ទងទៅនឹងគោលនយោបាយការការពារកុមារនេះបាន។

គោលនយោបាយការពារកុមារ និងគោលការណ៍ពាក់ព័ន្ធនានាដូចជា ក្រមសីលធម៌ការពារកុមារ និងដំណើរការណ៍ការពារកុមារនឹងត្រូវបានត្រួតពិនិត្យ ឬកែប្រែជាថ្មីរៀងរាល់ប្រាំឆ្នាំម្តងប្រសិនបើមានការចាំបាច់។

## គោលការណ៍ណែនាំសំរាប់អ្នកឧបត្ថម្ភកុមារ

ស៊ីស៊ីអេហ្វទទួលស្គាល់តម្រូវការជាក់លាក់ក្នុងការអនុវត្តគោលការណ៍ដើម្បីគ្រប់គ្រងលើការការពារកុមារពីហានិភ័យនានាសំរាប់កម្មវិធីឧបត្ថម្ភរបស់ខ្លួន។ ស៊ីស៊ីអេហ្វបានផ្តល់គោលការណ៍ណែនាំយ៉ាងលំអិតតាមរយៈគេហទំព័ររបស់ខ្លួនដល់អ្នកឧបត្ថម្ភ ដែលឯកសារមានចំណងជើងថា “សេចក្តីណែនាំស្តីពីអ្នកឧបត្ថម្ភជាមួយស៊ីស៊ីអេហ្វ”។ គោលការណ៍ណែនាំរបស់ស៊ីស៊ីអេហ្វក្នុងការទំនាក់ទំនងរវាងអ្នកឧបត្ថម្ភ និងកុមាររួមមានៈ

- រាល់ទំនាក់ទំនងរវាងកុមារ និងអ្នកឧបត្ថម្ភត្រូវបានត្រួតពិនិត្យដោយបុគ្គលិករបស់ស៊ីស៊ីអេហ្វ ហើយការទំនាក់ទំនងដែលមើលឃើញថាមិនសមរម្យមួយចំនួនមានដូចជា វប្បធម៌ នយោបាយ ឬសាសនា និងសម្ភារៈដែលអាចបង្កឲ្យមានបទល្មើសត្រូវបានហាមឃាត់យ៉ាងតឹងរឹងមិនអនុញ្ញាតឲ្យយកចូលកម្មវិធីរបស់ស៊ីស៊ីអេហ្វឡើយ។
- រាល់ការទស្សនៈកិច្ចរបស់អ្នកឧបត្ថម្ភត្រូវបានរៀបចំទុកជាមុនតាមរយៈការិយាល័យផ្នែកឧបត្ថម្ភរបស់ស៊ីស៊ីអេហ្វ។
- អ្នកឧបត្ថម្ភទាំងអស់នឹងត្រូវបានឆ្លងកាត់ការសម្ភាសន៍មុនពេលមកទស្សនៈកិច្ចត្រូវអានពី គោលនយោបាយការពារកុមារ និងចុះហត្ថលេខាលើក្រមសីលធម៌ការពារកុមាររបស់ស៊ីស៊ីអេហ្វ។
- ការដើរកំសាន្តតាមផ្សារ ឬទិញតវ៉ាន់មិនថាពេលព្រឹក ឬពេលល្ងាចនៅខាងក្រៅការគ្រប់គ្រងរបស់ស៊ីស៊ីអេហ្វគឺអនុញ្ញាតអោយតែកុមារដែលមានអាយុសមស្របប៉ុន្នោះដែលអាចទៅបាន។
- បុគ្គលិករបស់ស៊ីស៊ីអេហ្វនឹងទៅអមជាមួយកំឡុងពេលទស្សនៈរបស់អ្នកឧបត្ថម្ភ និងកំឡុងពេលចេញទៅខាងក្រៅ។
- អ្នកឧបត្ថម្ភ និងកុមារដែលទទួលបានការឧបត្ថម្ភព្រមទាំងក្រុមគ្រួសាររបស់ពួកគេមិនអនុញ្ញាតឲ្យធ្វើការផ្លាស់ប្តូរលេខទំនាក់ទំនងកំឡុងពេលទស្សនៈកិច្ចនោះឡើយ។
- មិនអនុញ្ញាតឲ្យអ្នកឧបត្ថម្ភអញ្ជើញកុមារឬនាំកុមារទៅឆ្ងាញពីសហគមន៍របស់ពួកគេរស់នៅនោះឡើយ។

## ការរាយការណ៍ និង ការឆ្លើយតប

ក្នុងករណីមានឧប្បត្តហេតុ មតិយោបល់ ការសង្ស័យ ឬការព្រួយបារម្ភណាមួយកើតឡើង ត្រូវតែរាយការណ៍ភ្លាមៗដល់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ស៊ីស៊ីអេហ្វដើម្បីចាប់ផ្តើមបើកការស៊ើបអង្កេត។ រាល់ករណីរំលោភបំពាននឹងត្រូវបានស៊ើបអង្កេតយ៉ាងយកចិត្តទុកដាក់បំផុតតាមនីតិវិធីដែលបានបង្កើត។ ការឆ្លើយតបទៅនឹងការព្រួយបារម្ភឬការចោទប្រកាន់ចំពោះគ្រោះថ្នាក់ ឬរំលោភបំពាន នៅចុងបញ្ចប់គោលការណ៍ណែនាំដែលបានចែងត្រូវយកមក អនុវត្តហើយផ្តោតសំខាន់ទៅលើផលប្រយោជន៍របស់កុមារ សុខុមាលភាពរបស់កុមារ និងការចូលរួមរបស់កុមារជាចម្បង។

នៅពេលកុមារបានរាយការណ៍ពីការព្រួយបារម្ភ ឬអះអាងថាមានការរំលោភបំពាន ពួកគេនឹងត្រូវបានការពារចាត់វិធានការយ៉ាងតឹងរ៉ឹងដើម្បីរកដំណោះស្រាយប្រកបដោយការគោរព។ គាត់ ឬនាងនឹងត្រូវយកចិត្តទុកដាក់ដោយមិនមានការស្តីបន្ទោស គាត់ ឬនាងនឹងមិនត្រូវបានបង្ហាញអោយឃើញពីការមិនជឿជាក់ ឬឥរិយាបថណាមួយដែលធ្វើឲ្យពួកគេមានការអៀនខ្មាស ឬអាម៉ាស់នោះឡើយ។ ស៊ីស៊ីអេហ្វនឹងធ្វើការជំលៀសកុមារចេញពីទីកន្លែងដែលទទួលរងនូវការរំលោភបំពាននោះភ្លាមៗដើម្បីស្វែងរកសេវាព្យាបាលពីរបួសស្នាម និងបញ្ជូនទៅកាន់សេវាដែលទាក់ទងបន្តក្នុងករណីចាំបាច់។

ក្នុងករណីមានការចោទប្រកាន់បង្ហាញថាគ្មានមូលដ្ឋានឬមិនពិត នោះនឹងគ្មានវិធានការណាមួយនឹងត្រូវបានធ្វើឡើងដើម្បីប្រឆាំងទៅនឹងអ្នកដែលត្រូវចោទប្រកាន់នោះទេ។

ការចោទប្រកាន់ ក្នុងន័យព្យាបាទដល់អ្នកដទៃប្រាស់ចាកពីការពិត ដែលមិនអាចទទួលយកបាននោះទេ នឹងមានវិធានការសមស្របត្រូវបានធ្វើឡើងភ្លាមៗសំរាប់អ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋ។ ការខកខានរបស់អ្នកតំណាងស៊ីស៊ីអេហ្វមិនរាយការណ៍ពីករណីសង្ស័យថាកុមារត្រូវបានរំលោភបំពានត្រូវបានចាត់ទុកជាអ្នកប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬជាលទ្ធផលត្រូវបញ្ឈប់ពីការងារ។

បុគ្គលិក និងមន្ត្រីទំនាក់ទំនងរបស់ ស៊ីស៊ីអេហ្វទាំងអស់នឹងត្រូវបានដឹងអំពីដំណើរការរាយការណ៍អំពីកុមារ។ ប្រធានផ្នែកការពារកុមារនឹងទទួលខុសត្រូវចំពោះការផ្សព្វផ្សាយ និងការស៊ើបអង្កេតរាល់ពាក្យបណ្តឹងដំបូង ដោយមានជំនួយពីនាយកគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការ នឹងធ្វើការវាយតម្លៃលើការចោទប្រកាន់នេះ ហើយចាត់វិធានការសមស្របដែលអាចរាប់ចាប់ពីករណីដែលគ្មានសកម្មភាព ការគ្រប់គ្រងអាកប្បកិរិយា ការប្រឹក្សាយោបល់ ការបញ្ជូនពាក្យបណ្តឹងទៅសមត្ថកិច្ចមូលដ្ឋាន/ប៉ូលីស និងការបញ្ឈប់ពីការងា។

របាយការណ៍ដែលសង្ស័យថាបានប្រាសចាកលើគោលការណ៍នេះ ឬឥរិយាបថផ្សេងទៀតដែលពាក់ព័ន្ធ អាចធ្វើការរាយការណ៍ទៅកាន់អ៊ីម៉ែល **safeguarding@cambodianchildrensfund.org**

# ក្រមសីលធម៌ការពារកុមារ

## ឧបសម្ព័ន្ធក១

### បុគ្គលិក អ្នកជាប់កិច្ចសន្យា អ្នកប្រឹក្សាយោបល់ និងអ្នកស្ម័គ្រចិត្ត

ខ្ញុំ ______________________ (ឈ្មោះ) យល់ព្រមអនុវត្តតាមកិច្ចព្រមព្រៀងក្រមសីលធម៌ការពារកុមាររបស់អង្គការមូលនិធិកុមារកុមារកម្ពុជា។

**ខ្ញុំនឹង:**

- ប្រព្រឹត្តជាមួយកុមារ និងមនុស្សវ័យក្មេងប្រកប ដោយការគោរពមិនថា ពណ៌សម្បុរ ភេទ ភាសា ពិការភាព សាសនា នយោបាយ ឬជំនឿផ្សេងៗ ជាតិសាសន៍ ប្រវត្តិសង្គម ឬប្រភពដើមកំណើត ឬស្ថានភាពផ្សេងៗឡើយ។
- ផ្តល់ការស្វាគមន៍ និងបរិស្ថានសុវត្ថិភាពដល់កុមារ មនុស្សវ័យក្មេង ឪពុកម្តាយកុមារ គ្រួសារ អ្នកផ្តល់ការមើលថែកុមារ បុគ្គលិក និងអ្នកស្ម័គ្រចិត្ត។
- លើកទឹកចិត្តដល់កុមារ មនុស្សវ័យក្មេង គ្រួសារ ឪពុកម្តាយកុមារ អ្នកមើលថែកុមារ បុគ្គលិក និងអ្នកស្ម័គ្រចិត្តលើកឡើងពីបញ្ហាដែលប៉ះពាល់ដល់ពួកគេ
- ជៀសវាងការដាក់ទណ្ឌកម្មលើរាងកាយរបស់កុមារជាឧបករណ៍ក្នុងការអប់រំដល់កុមារ។
- រាយការណ៍ភ្លាមៗពីការព្រួយបារម្ភ ឬការចោទប្រកាន់ការរំលោភបំពានលើកុមារស្របតាមដំណើរនៃការរាយការណ៍ ការពារកុមាររបស់អង្គការមូលនិធិកុមារកម្ពុជា។
- អនុវត្តតាមច្បាប់ការពារកុមារក្នុងតំបន់ ច្បាប់ប្រទេស និងច្បាប់អន្តរជាតិ។
- ធានាថា នៅពេលខ្ញុំកំពុងធ្វើការជាមួយកុមារ ឬនៅក្បែរកុមារមានវត្តមានបុគ្គលិកផ្សេងទៀតនៅក្បែរ។
- សុំការណែនាំពីប្រធានរបស់ខ្ញុំប្រសិនបើសកម្មភាពដែលខ្ញុំបានធ្វើអាចប្រាសចាកពីគោលការណ៍។
- សុំការណែនាំពីប្រធានរបស់ខ្ញុំប្រសិនបើខ្ញុំពាក់ព័ន្ធជាមួយស្ថានភាពណាមួយដែលអាចនាំផលអាក្រក់ដល់អង្គការឬស្ថាប័ន។
- សុំការណែនាំពីប្រធានរបស់ខ្ញុំប្រសិនខ្ញុំត្រូវបានរកឃើញថាជាប់ពាក់ព័ន្ធបទឧក្រិដ្ឋ ឬការចោទប្រកាន់ណាមួយទៅនឹងបទល្មើស។

**ខ្ញុំនឹងមិន:**

- ប្រើភាសាមិនសមរម្យមួយចំនួននិយាយទៅកាន់កុមារ ឬមនុស្សវ័យក្មេង ដូចជា ប្រមាថ រើសអើង បន្ទោសបង្អាប់ រំលោភបំពាន ឬបែបផ្លូវភេទនៅពេលមានវត្តមានកុមារ ឬមនុស្សវ័យក្មេង។
- បញ្ចេញឥរិយាបថ ដែលធ្វើឲ្យកុមារ ឬមនុស្សវ័យក្មេងមានការខ្មាស់អៀន អាម៉ាស់ មើលងាយ ឬស្តីបន្ទោសដែលចាត់ទុកជាការរំលោភបំពានផ្លូវចិត្តរបស់កុមារ ឬមនុស្សវ័យក្មេងជាដើម។
- រៀបការជាមួយមនុស្សដែលមានអាយុក្រោម១៨ឆ្នាំ។
- បញ្ចេញសកម្មភាពបែបលក្ខណៈផ្លូវភេទ ឬចូលរួមសកម្មភាពណាមួយបែបផ្លូវភេទជាមួយកុមារព្រមទាំងការបង់ថ្លៃសេវាផ្លូវភេទជាដើម។
- បញ្ចេញសកម្មភាព តាមបែបវប្បធម៌ដែលមិន សមរម្យ ឬមិនចាំបាច់ជាមួយកុមារ ដូចជា អោប ថើប ថ្នាក់ថ្នម ឬប៉ះពាល់។
- លើកលែងទោស ឬចូលរួមធ្វើសកម្មភាពដែលខុសច្បាប់ គ្មានសុវត្ថិភាព ឬរំលោភបំពានកុមារ។
- រើសអើងប្រឆាំងទៅនឹងកុមារ ឬយកចិត្តទុកដាក់លើកុមារម្នាក់ជាងកុមារដទៃទៀត។
- ចំណាយពេលក្រៅម៉ោងការងារទំនាក់ទំនងជាមួយកុមារ ឬមនុស្សវ័យក្មេងណាម្នាក់ក្នុងកម្មវិធីរបស់អង្គការមូលនិធិកុមារកម្ពុជា។
- នាំកុមារទៅផ្ទះរបស់អ្នក ឬអនុញ្ញាតឲ្យកុមារទៅផ្ទះរបស់ពួកគេតែម្នាក់ឯងលុះត្រាតែពួកគេស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បន្ទាន់ណាមួយ។
- ទទួលកុមារឲ្យធ្វើការតាមផ្ទះ ឬការងារណាមួយដែលពួកគេមិនទាន់គ្រប់អាយុដែលបង្អាក់ដល់ការសិក្សា អភិវឌ្ឍ ការកំសាន្ត ឬបង្កជាហានិភ័យនិងរបួសស្នាមដល់កុមារ។
- ជួយធ្វើការងារណាដែលកុមារអាចធ្វើបានដោយខ្លួនឯងដូចជា ស្អិតស្អាងខ្លួន ចូលបន្ទប់ទឹក ឬផ្លាស់ប្តូរសំលៀកបំពាក់ឲ្យកុមារ។
- គេងនៅក្បែរកុមារ លុះត្រាតែជាករណីចាំបាច់ ប្រសិនបើមាន ខ្ញុំនឹងជូនដំណឹងដល់ប្រធានរបស់ខ្ញុំតាមដែលអាចធ្វើបាន និងធានាថាមានវត្តមានបុគ្គលិកម្នាក់ទៀតនៅទីនោះ(កំណត់ចំណាំរាល់សកម្មភាពនេះមិនសំដៅដល់កូនបង្កើតរបស់ខ្ញុំទេ)។
- ចូលគេហទំព័ររូបភាពបែបរំលោភបំពានផ្លូវភេទរបស់កុមារ។
- ប្រើប្រព័ន្ធបច្ចេកវិទ្យាដូចជា កុំព្យូទ័រ ទូរស័ព្ទដៃ វីដេអូ ម៉ាស៊ីនថតរូប និងសម្ភារៈផ្សេងៗក្នុងគោលបំណងកេងប្រវ័ញ្ច ឬបៀតបៀនលើកុមារ។

## ការសម្ងាត់ និងបញ្ញត្តិនៃការថតរូប

ស៊ីស៊ីអេហ្វ ចាត់ទុកថាការការពារកុមារ គឺជាការងារសំខាន់បំផុត។ ស៊ីស៊ីអេហ្វ ធ្វើការជាមួយមនុស្សគ្រប់ វ័យជាច្រើន ដែលមានស្ថានភាពផ្សេងៗគ្នាតាមរយៈ គំរោង និងកម្មវិធីដែលខ្លួនមាន ដើម្បីគាំទ្រដល់ពួកគេ។ គ្រប់ស្ថានភាពទាំងអស់ ការផ្តល់ព័ត៌មានមានសារៈសំខាន់បំផុតនៅពេលដែលមានព័ត៌មានគ្រប់គ្រាន់ ហើយកុមារដែលនៅក្នុងស៊ីស៊ីអេហ្វនឹងទទួលបានការយកចិត្តទុកដាក់នឹងត្រូវបានការពារកាន់តែខ្លាំង និងប្រកបដោយប្រសិទ្ធភាព។ ដោយសារតែ ព័ត៌មាន ទាក់ទងទៅនឹងនីតិវិធីការការពារកុមាររបស់ស៊ីស៊ីអេហ្វមានការផ្សព្វផ្សាយដល់អន្តរជាតិពីការ អនុវត្តតាមច្បាប់អន្តរជាតិពាក់ព័ន្ធដូចខាងក្រោមៈ

- ច្បាប់ការពារភាពឯកជនតាមប្រព័ន្ធអនឡាញ ឆ្នាំ២០០៣ កាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក
- ច្បាប់ឯកជនភាពឆ្នាំ ១៩៨៨ ប្រទេសអូស្ត្រាលី
- ច្បាប់ការពារទិន្នន័យ ឆ្នាំ១៩៨៨ ចក្រភពអង់គ្លេស
- សេចក្តីណែនាំស្តីពីការការពារទិន្នន័យសហគមន៍អឺរ៉ុប (សេចក្តីបង្គាប់ 95/46/EC)

## ការសម្ងាត់

បុគ្គលិករបស់ស៊ីស៊ីអេហ្វទាំងអស់រួមទាំងអ្នកស្ម័គ្រចិត្ត ភ្ញៀវ និងអ្នកដែលជាប់ពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពផ្សេងៗសុទ្ធតែមានតួនាទីចែករំលែកព័ត៌មានពីការ ការពារកុមាររបស់ស៊ីស៊ីអេហ្វ។ ស៊ីស៊ីអេហ្វ មានសមត្ថភាពក្នុងការចែករំលែកព័ត៌មាន និងអនុញ្ញាតឲ្យប្រើប្រាស់រូបថត វីដេអូ ឬវិធីសាស្ត្រស្រដៀងគ្នាតាមកិច្ច ព្រមព្រៀង និងលក្ខខណ្ឌដែលចែងដូចខាងក្រោម។

**ខ្ញុំសន្យាថាៈ**

- ទទួលស្គាល់ពីតម្រូវការរបស់ស៊ីស៊ីអេហ្វ ក្នុងការរក្សាទុករាល់ទិន្ន័យ និងព័ត៌មានសំខាន់ៗដែលទាក់ទងទៅនឹងបុគ្គលិក អង្គការ ខ្លួនឯង និងភាគីដែលពាក់ព័ន្ធ ហើយខ្ញុំទទួលស្គាល់ពីកាតព្វកិច្ចផ្ទាល់ខ្លួនក្នុងការរក្សាការសម្ងាត់ព័ត៌មានទាំងនេះ។
- កំឡុងពេល និងបន្ទាប់ពីការចូលរួមរបស់ខ្ញុំនៅ ស៊ីស៊ីអេហ្វ ខ្ញុំអាចក្លាយជាអ្នកដែលរក្សាព័ត៌មានសម្ងាត់ ឧទាហរណ៍ ព័ត៌មានទាក់ទង នឹងផ្នែកហិរញ្ញវត្ថុ បុគ្គលិក គំរោង ផែនការ ឬបញ្ហាផ្សេងៗរបស់ស៊ីស៊ីអេហ្វ។ ខ្ញុំសន្យាថា នឹងរក្សាព័ត៌មានរបស់ស៊ីស៊ីអេហ្វដែលខ្ញុំបាន ដឹង ឬរកឃើញខ្ញុំត្រូវរក្សាការសម្ងាត់ និងប្រើវាយ៉ាងយកចិត្តទុកដាក់បំផុត និងមិនបង្ហាញឲ្យ
- ខុសពីធម្មតាប្រសិនបើមិនមានករណីចាំបាច់របស់ខ្ញុំជាមួយស៊ីស៊ីអេហ្វដោយគ្មានក្នុងកិច្ចព្រមព្រៀង។
- នៅពេលខ្ញុំក្លាយជាភាគីទីបីដែលដឹងព័ត៌មានពាក់ព័ន្ធ ឬជាប់ទាក់ទងទៅនឹងអង្គការ បុគ្គល និងឯកជនជាមួយ
- ស៊ីស៊ីអេហ្វខ្ញុំសន្យាថា នឹងរក្សាព័ត៌មានសម្ងាត់ មិនបង្កើត ឬស្វែងរកព័ត៌មាន និងប្រើប្រាស់សម្ភារៈណាដោយគ្មានការអនុញ្ញាត ត្រឹមត្រូវពីស៊ីស៊ីអេហ្វ។
- ប្រសិនបើខ្ញុំ ចង់សរសេរព័ត៌មានណាមួយពីស៊ីស៊ី អេហ្វក្នុងគោលបំណងផ្សព្វផ្សាយ ចងក្រងជាឯកសារបង្រៀន ឬសកម្មភាពស្រដៀងគ្នាដែលមានការ ប៉ះពាល់ ឬផលមិនល្អដល់ស៊ីស៊ីអេហ្វ ខ្ញុំនឹងស្វែងរកកិច្ចនូវព្រមព្រៀងជាលាយលក្ខណ៍ជាអក្សរជាក់លាក់ពីបុគ្គលិករបស់ស៊ីស៊ីអេហ្វដែលបង្ហាញពីព័ត៌មាន ត្រឹមត្រូវតាមតម្រូវការច្បាប់ដែលបានកំណត់ច្បាស់លាស់។

## ការថតរូប និងប្រើប្រាស់វីដេអូ

- មុនពេលថតរូប ឬសរសេររឿងរ៉ាវរបស់កុមារណាម្នាក់សំរាប់គោលបំណងទាក់ទងទៅនឹងការងារ ខ្ញុំនឹងធ្វើការវាយតម្លៃ និងអនុវត្ត តាមប្រពៃណីក្នុងតំបន់យ៉ាងតឹងរ៉ឹងចំពោះការផលិតរូបភាពផ្ទាល់ខ្លួនឡើងវិញ។
- ខ្ញុំនឹងមិន ថតរូបដោយគ្មានការយល់ព្រមជាមុនពីបុគ្គលិករបស់ស៊ីស៊ីអេហ្វ ដាក់ឈ្មោះនាយប្រតិបត្តិ ប្រធានកម្មវិធី ឬប្រធានសាខា នោះឡើយ។
- កិច្ចព្រមព្រៀងដែលខ្ញុំស្នើសុំថតរូប ឬថតជាសារ សម្លេងរបស់នរណាម្នាក់នឹងត្រូវពិចារណា និងរៀបចំទុកជាមុនព្រមទាំងបញ្ជាក់យ៉ាងច្បាស់ពី លទ្ធផលសម្ភារៈដែលនឹងត្រូវប្រើប្រាស់។
- ខ្ញុំនឹងផ្តល់ការគោរពសេចក្តីថ្លៃថ្នូរដល់អ្នកដែលខ្ញុំសុំស្នើថតរូប ឬថតជាសារសម្លេងដោយផ្ទាល់។
- ខ្ញុំធានាថា រូបថត ឬវីដេអូរបស់កុមារដែលខ្ញុំបានថតមានសម្លៀកបំពាក់សមរម្យ។
- ខ្ញុំនឹងមិនថតរូប ឬព្យាយាមចូលទៅថតរូបនៅកន្លែងដែលគ្មានការអនុញ្ញាត ឬមិនត្រូវឲ្យដឹង និងគ្មានសិទ្ធិឲ្យចូលថតរូបនៅ កន្លែងគេង កន្លែងងូតទឹក ឬនៅពេលដែលកុមារកំពុងតែមានទុក្ខព្រួយនោះឡើយ។
- ខ្ញុំនឹងមិនចំណាយពេលថតសម្លេង ឬវីដេអូដែលស្នើឡើងតាមបែបផ្លូវភេទរបស់កុមារនោះឡើយ។
- ខ្ញុំនឹងមិនប្រើរូបភាពជាសាធារណៈ(blog) ក្នុងគោលបំណងកេងប្រវ័ញ្ចដោយគ្មានការស្នើសុំការអនុញ្ញាតពីស៊ីស៊ីអេហ្វមុននោះឡើយ។
- ខ្ញុំនឹងធានាថា ឈ្មោះឯកសារមិនបង្ហាញឲ្យដឹងពីព័ត៌មាន និងអត្តសញ្ញាណរបស់កុមារនៅពេលបញ្ជូនទៅប្រព័ន្ធអេឡិចត្រូនិច។

ខ្ញុំបានអាន យល់ពីតម្រូវការរបស់ស៊ីស៊ីអេហ្វ និងសន្យាអនុវត្តតាមតម្រូវការដែលបានរៀបរាប់ខាងលើ។

## គោលការណ៍នេះបានចុះហត្ថលេខាជាផ្លូវការណ៍ដោយ បុគ្គលិកទាំងអស់ អ្នកជាប់កិច្ចសន្យា អ្នកប្រឹក្សា និងអ្នកស្ម័គ្រចិត្តរបស់ស៊ីស៊ីអេហ្វ

ខ្ញុំធានាអះអាង ថាខ្ញុំបានអាន និងយល់ពីអង្គការមូលនិធិកុមារកម្ពុជាៈ

- **គោលនយោបាយការពារកុមារ**
- **ក្រមសីលធម៌ការពារកុមារ**

ខ្ញុំយល់ព្រមអនុវត្តតាមគោលការណ៍ និងក្រមសីលធម៌ការពារកុមារ។ ខ្ញុំយល់ថា ការប្រព្រឹត្តដែលប្រាស់ចាកពីគោលការណ៍ឬក្រមសីលធម៌ការពារ កុមារអាចនឹងផ្តល់ផលមិនល្អ និងបញ្ឈប់ការងាររបស់ខ្ញុំពីស៊ីស៊ីអេហ្វ។ ខ្ញុំយល់ថា ការប្រព្រឹត្តដែលប្រាស់ចាក់ពីគោលការណ៍ ឬក្រមសីលធម៌ ការពារកុមារជាលទ្ធផលជាប់ពីបទឧក្រិដ្ឋ។

ខ្ញុំយល់ពីទំនួលខុសត្រូវរបស់ខ្ញុំក្នុងនាមជាបុគ្គលិកដែលបំរើការងារជាមួយអង្គការមូលនិធិកុមារកម្ពុជាខ្ញុំយល់ពីផលប្រយោជន៍រួម និងជៀសវាងការប្រព្រឹត្តសកម្មភាពឬឥរិយាបថដែលបង្កអោយមានការរំលោភបំពាន កេងប្រវ័ញ្ចលើកុមារ ឬមនុស្សវ័យក្មេង។

ខ្ញុំយល់ព្រម អោយអង្គការមូលនិធិកុមារកម្ពុជាធ្វើការស៊ើបអង្កេតចំពោះតម្រូវការចាំបាច់ ដូចជាលិខិតថ្កោលទោស អ្នកធានា។ ខ្ញុំសូមអះអាងថា ខ្ញុំមានឆន្ទៈដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការការពារកុមាររបស់អង្គការមូលនិធិកុមារកម្ពុជា។

ឈ្មោះៈ ________________________________

តួនាទីៈ ________________________________

ហត្ថលេខាៈ ______________________________

ថ្ងៃទី ខែ ឆ្នាំៈ ____________________________

# ឧបសម្ព័ន្ធក២
## សំរាប់ភ្ញៀវ

ខ្ញុំ ____________________ (ឈ្មោះ)យល់ព្រមអនុវត្តតាមកិច្ចព្រមព្រៀងក្រមសីលធម៌ការពារកុមាររបស់អង្គការមូលនិធិកុមារកុមារកម្ពុជា។

**ខ្ញុំនឹង:**

- ប្រព្រឹត្តជាមួយកុមារ និងមនុស្សវ័យក្មេងប្រកបដោយការគោរពដោយមិនថា ពណ៌សម្បុរ ភេទ ភាសា ពិការភាព សាសនា នយោបាយ ឬ ជំនឿផ្សេងៗ ជាតិសាសន៍ ប្រវត្តិសង្គម ឬប្រភពដើមកំណើត ឬស្ថានភាពផ្សេងៗឡើយ។
- ផ្តល់ការស្វាគមន៍ និងបរិស្ថានសុវត្ថិភាពដល់កុមារ មនុស្សវ័យក្មេង ឪពុកម្តាយកុមារ គ្រួសារ អ្នកផ្តល់ការមើលថែកុមារ បុគ្គលិក និងអ្នកស្ម័គ្រចិត្ត។
- លើកទឹកចិត្តដល់កុមារ មនុស្សវ័យក្មេង គ្រួសារ ឪពុកម្តាយកុមារ អ្នកមើលថែកុមារ បុគ្គលិក និងអ្នកស្ម័គ្រចិត្តលើកឡើងពីបញ្ហាដែលប៉ះពាល់ដល់ពួកគេ។
- ជៀសវាងការដាក់ទណ្ឌកម្មលើរាងកាយរបស់កុមារជាឧបករណ៍ក្នុងការអប់រំដល់កុមារ។
- រាយការណ៍ភ្លាមៗពីកាព្រួយបារម្ភឬការចោទប្រកាន់ពីការរំលោភបំពានលើកុមារស្របតាមដំណើរការណ៍រាយការណ៍ការពារកុមាររបស់អង្គការមូលនិធិកុមារកម្ពុជា។
- អនុវត្តតាមច្បាប់ការពារកុមារក្នុងតំបន់ ប្រទេស និងអន្តរជាតិ

**ខ្ញុំនឹងមិន:**

- ប្រើភាសាមិនសមរម្យមួយចំនួន និយាយទៅកាន់កុមារ ឬមនុស្សវ័យក្មេង ដូចជា ប្រមាថ រើសអើង បន្ទោសបង្អាប់រំលោភបំពាន ឬបែបផ្លូវភេទនៅពេលមានវត្តមានកុមារ ឬមនុស្សវ័យក្មេង។
- បញ្ចេញឥរិយាបថ ដែលធ្វើឲ្យកុមារ ឬមនុស្សវ័យក្មេងមានការខ្មាសអៀន អាម៉ាស់ មើលងាយ ឬស្តីបន្ទោសដែលចាត់ទុកជាការរំលោភបំពានផ្លូវចិត្តរបស់កុមារ ឬមនុស្សវ័យក្មេង។
- បញ្ចេញសកម្មភាពបែបលក្ខណៈផ្លូវភេទ ឬចូលរួមសកម្មភាពណាមួយបែបផ្លូវភេទជាមួយកុមារព្រមទាំងការបង់សោ ផ្លូវភេទជាដើម។
- បញ្ចេញសកម្មភាពតាមបែបវប្បធម៌ដែលមិនសមរម្យ ឬមិនចាំបាច់ជាមួយកុមារ ដូចជា អោប ថើប ថ្នាក់ថ្នម ឬ ប៉ះពាល់។
- លើកលែងទោសឲ្យ ឬចូលរួមធ្វើសកម្មភាពដែលខុសច្បាប់ គ្មានសុវត្ថិភាព ឬរំលោភបំពានជាមួយ កុមារ។
- រើសអើងប្រឆាំងទៅនឹងកុមារ ឬយកចិត្តទុកដាក់លើកុមារម្នាក់ជាងកុមារដទៃទៀត។
- ចំណាយពេលខាងក្រៅម៉ោងការងារទំនាក់ទំនងជាមួយកុមារ ឬមនុស្សវ័យក្មេងណាម្នាក់ក្នុងកម្មវិធីរបស់អង្គការមូលនិធិកុមារកម្ពុជា។
- ទទួលកុមារឲ្យធ្វើការតាមផ្ទះ ឬការងារណាមួយដែលពួកគេមិនទាន់គ្រប់អាយុដែលបង្អាក់ដល់ការ សិក្សា អភិវឌ្ឍ ការកំសាន្ត ឬ បង្កជាហានិភ័យ និងរបួសស្នាមដល់កុមារ។
- ជួយធ្វើការងារណាដែលកុមារអាចធ្វើបានដោយខ្លួនឯងដូចជា ស្អិតស្អាងខ្លួន ចូលបន្ទប់ទឹក ឬផ្លាស់ប្តូរ សម្លៀកបំពាក់ឲ្យកុមារ។
- ចូលគេហទំព័ររូបភាពបែបរំលោភបំពានផ្លូវភេទរបស់កុមារ។
- ប្រើប្រព័ន្ធបច្ចេកវិទ្យាដូចជា កុំព្យូទ័រ ទូរស័ព្ទដៃ វីដេអូ ម៉ាស៊ីនថតរូប និងសម្ភារៈផ្សេងៗក្នុងគោលបំណងកេងប្រវ័ញ្ច ឬបៀតបៀនលើកុមារ។

## ការសម្ងាត់ និងបញ្ញត្តិនៃការថតរូប

ស៊ីស៊ីអេហ្វចាត់ទុកថា ការការពារកុមារគឺជាការងារសំខាន់បំផុត។ ស៊ីស៊ីអេហ្វ ធ្វើការជាមួយមនុស្សគ្រប់វ័យជាច្រើនដែលមានស្ថានភាពផ្សេងៗគ្នាតាមរយៈ គំរោង និងកម្មវិធីដែលខ្លួនមានដើម្បីគាំទ្រដល់ពួកគេ។ គ្រប់ស្ថានភាពទាំងអស់ ការផ្តល់ព័ត៌មានមានសារៈសំខាន់បំផុតនៅពេលដែលមានព័ត៌មានគ្រប់គ្រាន់ ហើយកុមារដែលនៅក្នុងស៊ីស៊ីអេហ្វនឹងទទួលបានការយកចិត្តទុកដាក់ និងត្រូវបានការពារកាន់តែខ្លាំង ប្រកបដោយប្រសិទ្ធភាព។ ដោយសារតែព័ត៌មានទាក់ទងទៅនឹងនីតិវិធីការការពារកុមាររបស់ស៊ីស៊ីអេហ្វមានការផ្សព្វផ្សាយដល់អន្តរជាតិពីការអនុវត្តតាមច្បាប់អន្តរជាតិពាក់ព័ន្ធដូចខាងក្រោម:

- **ច្បាប់ការពារភាពឯកជនតាមប្រព័ន្ធអនឡាញឆ្នាំ២០០៣ កាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក**
- **ច្បាប់ឯកជនភាពឆ្នាំ ១៩៨៨ ប្រទេសអូស្រ្តាលី**
- **ច្បាប់ការពារទិន្នន័យឆ្នាំ ១៩៨៨ ចក្រភពអង់គ្លេស**
- **សេចក្តីណែនាំស្តីពីការការពារទិន្នន័យសហគមន៍អឺរ៉ុប (សេចក្តីបង្គាប់ 95/46/EC)**

តាមរយៈការរៀបរាប់ខាងលើស៊ីស៊ីអេហ្វស្នើសុំអោយភ្ញៀវទាំងអស់ទទួលបន្ទុកក្នុងការចែករំលែកព័ត៌មានស្តីពីការការពារកុមាររបស់យើង។ សមត្ថភាពរបស់ស៊ីស៊ីអេហ្វគឺចែករំលែកព័ត៌មានជាមួយអ្នកនិងអនុញ្ញាតឱ្យអ្នកកត់ត្រាដំណើរទស្សនកិច្ចរបស់អ្នកជាមួយនឹងរូបថត ឬវីដេអូ ឬវិធីសាស្រ្តស្រដៀងគ្នាអាស្រ័យលើកិច្ចព្រមព្រៀងរបស់អ្នកជាមួយនឹងលក្ខខណ្ឌដែលបានចែងដូចខាងក្រោម។

## ការថតរូប

ស៊ីស៊ីអេហ្វ ពេញចិត្តនិងជឿទុកចិត្តមានកម្រិតក្នុងការអនុញ្ញាតអោយយើងចូលទៅក្នុងកន្លែងដែលអ្នកផ្សេងទៀតមិនត្រូវបានស្វាគមន៍ ឬអនុញ្ញាតអោយចូល។ យើងត្រូវគោរពលើការជឿទុកចិត្តហើយកុំបំពានលើការជឿទុកចិត្តនេះ។ ដូចគ្នានឹងភ្ញៀវដែលមកលេងណាមួយគ្រួសារគឺត្រូវបានស្វាគមន៍ និងការកត់ត្រានៃការមកលេងរបស់ពួកគេដោយរួមបញ្ចូលទាំងការប្រើប្រាស់កាយវិការសមរម្យ និងអារម្មណ៍ល្អៗដើម្បីជៀសវាងការលំបាកកើតឡើងនៅជុំវិញទីកន្លែងនោះ ស៊ីស៊ីអេហ្វស្នើអោយភ្ញៀវទាំងអស់ប្រើប្រាស់កម្រិតដូចគ្នានៅពេលពួកគេទៅលេងគ្រួសាររបស់ខ្លួន។ ស៊ីស៊ីអេហ្វទាមទារអោយភ្ញៀងទាំងអស់គោរព និងអនុវត្តតាមគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន និងរូបថតរបស់ភាពបុគ្គលដែលបានចែងខាងលើផងដែរ។

## សូមអានកិច្ចព្រមព្រៀងទាំងអស់ខាងក្រោមហើយចុះហត្ថលេខាលើកិច្ចព្រមព្រៀងរបស់អ្នកនៅកន្លែងដែលបានបញ្ជាក់។

## ការសម្ងាត់

### ខ្ញុំសន្យាថា:

- ទទួលស្គាល់ពីតម្រូវការរបស់ស៊ីស៊ីអេហ្វក្នុងការរក្សាទុករាល់ទិន្នន័យ និងព័ត៌មានសំខាន់ៗដែលទាក់ទងទៅនឹងបុគ្គលិក អង្គការខ្លួនឯង និងភាគីដែលពាក់ព័ន្ធហើយខ្ញុំទទួលស្គាល់ពីកាតព្វកិច្ចផ្ទាល់ខ្លួនក្នុងការរក្សាការសម្ងាត់ទាំងនេះ។
- កំឡុងពេល និងបន្ទាប់ពីការចូលរួមរបស់ខ្ញុំនៅស៊ីស៊ីអេហ្វ ខ្ញុំអាចក្លាយជាអ្នកដែលរក្សាព័ត៌មានសម្ងាត់ ឧទាហរណ៍ព័ត៌មានទាក់ទងហិរញ្ញវត្ថុរបស់ស៊ីស៊ីអេហ្វ បុគ្គលិក គំរោង ផែនការ ឬបញ្ហានានា។ ខ្ញុំសន្យាថា នឹងរក្សាព័ត៌មានរបស់ស៊ីស៊ីអេហ្វដែលខ្ញុំបានដឹងឮ ឬរកឃើញខ្ញុំនឹងរក្សាការសម្ងាត់បំផុត និងមិនលាតត្រដាងឬប្រើប្រាស់ព័ត៌មានលើសពីធម្មតា និងចាំបាច់ក្នុងតួនាទីរបស់ខ្ញុំជាមួយស៊ីស៊ីអេហ្វដែលគ្មាននៅក្នុងកិច្ចព្រៀងរបស់ស៊ីស៊ីអេហ្វ។
- នៅពេលខ្ញុំក្លាយជាភាគីទីបីដែលដឹងព័ត៌មានពាក់ព័ន្ធទៅនឹងអង្គការបុគ្គលផ្សេងទៀតជាមួយស៊ីស៊ីអេហ្វ ខ្ញុំសន្យារក្សាព័ត៌មានសម្ងាត់ និងមិនបង្កើត ឬស្វែងរកព័ត៌មានហើយប្រើប្រាស់សម្ភារៈណាមួយដោយគ្មានការអនុញ្ញាតជាក់លាក់ពីស៊ីស៊ីអេហ្វ។
- ប្រសិនបើខ្ញុំ ចង់សរសេរព័ត៌មានអ្វីមួយអំពីស៊ីស៊ីអេហ្វដើម្បីផ្សព្វផ្សាយ ចងក្រងជាឯកសារបង្រៀនពីសកម្មភាពនានា ឬការប៉ះពាល់ ឬសកម្មភាពស្រដៀងគ្នាខ្ញុំនឹងស្វែងរកកិច្ចព្រមព្រៀងជាក់លាក់ចេញពីស៊ីស៊ីអេហ្វដែលមានជាលាយលាក់ជាអក្សរចេញពីបុគ្គលិករបស់ស៊ីស៊ីអេហ្វ។ ខ្ញុំនឹងបង្ហាញពីការទទួលខុសត្រូវដោយច្បាប់ជាកំហិត។

## ការថតរូប និងប្រើប្រាស់វីដេអូ

- មុនពេលថតរូប ឬភាពយន្តពីកុមារសំរាប់គោលបំណងដែលទាក់ទងទៅនឹងការងារខ្ញុំ នឹងធ្វើការប៉ាន់ប្រមាណ និងអនុវត្តតាមប្រពៃណីក្នុងតំបន់ ឬការហាមតឹងរឹងពីការបោះពុម្ពផ្សាយរូបភាពផ្ទាល់ខ្លួន។
- ខ្ញុំនឹងមិនថតរូបដោយគ្មានការយល់ព្រមជាមុនពីបុគ្គលិករបស់ស៊ីស៊ីអេហ្វ និងដាក់ឈ្មោះនាយកប្រតិបត្ត ប្រធានកម្មវិធី ប្រធានសាខាឬមន្ត្រីផ្នែកឧបត្ថម្ភនោះឡើយ។
- កិច្ចព្រមព្រៀងដែលខ្ញុំស្នើសុំថតរូប ឬថតជាសារសម្លេងរបស់នរណាម្នាក់នឹងត្រូវពិចារណា និងរៀបចំទុកជាមុនព្រមទាំងបញ្ជាក់យ៉ាងច្បាស់ពីលទ្ធផលសម្ភារៈដែលនឹងត្រូវប្រើប្រាស់។
- ការថតរូបនិងការថតវីដេអូរបស់ខ្ញុំនឹងត្រូវបានកំណត់កម្រិតចាំបាច់គ្រប់គ្រាន់សំរាប់ការចងចាំនៃទស្សនៈកិច្ចរបស់ខ្ញុំ។
- ខ្ញុំនឹងផ្តល់ការគោរពសេចក្តីថ្លៃថ្នូរដល់អ្នកដែលខ្ញុំសុំស្នើថតរូប ឬថតជាសារសម្លេងដោយផ្ទាល់។
- ខ្ញុំធានាថា រូបថត ឬវីដេអូរបស់កុមារដែលខ្ញុំបានថតមានសម្លៀកបំពាក់សមរម្យ។
- ខ្ញុំនឹងមិនថតរូប ឬព្យាយាមចូលទៅថតរូបនៅកន្លែងដែលគ្មានការអនុញ្ញាតឬមិនត្រូវឲ្យដឹងនិងគ្មានសិទ្ធិឲ្យចូលថតរូបនៅកន្លែងគេង កន្លែងងូតទឹក ឬនៅពេលដែលកុមារកំពុងតែមានទុក្ខព្រួយនោះឡើយ។
- ខ្ញុំនឹងមិនចំណាយពេលថតសម្លេងឬវីដេអូដែលស្នើឡើងតាមបែបផ្លូវភេទរបស់កុមារនោះឡើយ។
- ខ្ញុំនឹងមិនប្រើរូបភាពជាសាធារណៈ(blog)ក្នុងគោលបំណងកេងប្រវ័ញ្ចដោយគ្មានការស្នើសុំការអនុញ្ញាតពីស៊ីស៊ីអេហ្វជាមុននោះឡើយ។
- ខ្ញុំធានាថា រូបថតរបស់ខ្ញុំបង្ហាញពីភាពស្មោះត្រង់ ការពិតនៅក្នុងបរិបទ។
- នៅពេលប្រើព័ត៌មានដែលទាក់ទងទៅនឹងស៊ីស៊ីអេហ្វលើប្រព័ន្ធផ្សព្វផ្សាយសង្គម ខ្ញុំនឹងត្រូវតែការពារភាពឯកជន ឬ បុគ្គលរបស់ស៊ីស៊ីអេហ្វ។ ខ្ញុំនឹងមិនផ្សព្វផ្សាយពីអាស័យដ្ឋានក៏ដូចជាឈ្មោះពិត និងប្រវត្តិបញ្ហារបស់កុមារដែលជាសិស្សស៊ីស៊ីអេហ្វនោះឡើយ។
- ខ្ញុំនឹងធានាថា ឈ្មោះឯកសារមិនបង្ហាញឲ្យដឹងពីព័ត៌មាន និងអត្តសញ្ញាណរបស់កុមារនៅពេលបញ្ជូនទៅប្រព័ន្ធអេឡិចត្រូនិច។

**ខ្ញុំបានអាន យល់ និងសន្យាអនុវត្តតាមការណែនាំខាងលើ។**

## គោលការណ៍បានចុះហត្ថលេខាដោយភ្ញៀវរបស់ស៊ីស៊ីអេហ្វ។

**ខ្ញុំធានាអះអាងថា បានអាននិងយល់ដឹងពីអង្គការមូលនិធិកុមារកម្ពុជា:**

- **គោលនយោបាយការពារកុមារ និង**
- **ក្រមសីលធម៌ការពារកុមារ**

ខ្ញុំយល់ព្រមអនុវត្តតាមគោលការណ៍ក្រមសីលធម៌ការពារកុមារ។

ឈ្មោះ: ________________________________

ហត្ថលេខា: ______________________________

ថ្ងៃទី ខែ ឆ្នាំ: _____________________________

# ដំណើរការរាយការណ៍ពីការការពារកុមារ

## ឧបសម្ព័ន្ធខ

**១ នរណាអាចរាយការណ៍បាន**

កុមារ/មនុស្សវ័យក្មេង

ឪពុក-ម្ដាយ/មនុស្សពេញវ័យ

បុគ្គលិក អ្នកស្ម័គ្រចិត្ត ឬអ្នកដែលជាប់ពាក់ព័ន្ធ

**២ រាយការណ៍ពីអ្វី?**

ការចោទប្រកាន់ទាក់ទងទៅនិងការរំលោភបំពានលើកុមារតាមរយៈការអង្កេត ឬសង្ស័យថាមានការប្រព្រឹត្តប្រាសចាកពីគោលការណ៍ការពារកុមារ និងក្រមសីលធម៌។

**៣ រាយការណ៍នៅពេលណា?**

រាល់ការព្រួយបារម្ភ ការចោទប្រកាន់ ឬរំលោភបំពានត្រូវរាយការណ៍ ២៤ ម៉ោង ឬកាន់តែឆាប់តាមដែលអាចធ្វើទៅបាន។

**៤ តើរាយការណ៍ទៅនរណា?**

រាល់ការចោទប្រកាន់រំលោភបំពានកុមារ សុវត្ថិភាព ឬ សុខុមាលភាពរបស់កុមារត្រូវរាយការណ៍ទៅប្រធានផ្នែកការពារកុមារ មន្ត្រីការពារកុមារ អ្នកគ្រប់គ្រងសាខា ឬសមាជិកណាមួយរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់។

របាយការណ៍គួរតែត្រូវរាយការណ៍:
safeguarding@cambodianchildrensfund.org

**៥ តើនឹងមានអ្វីកើតឡើង**

ស្ថានភាព និងរាល់ព័ត៌មាននិងត្រូវបានវាយតម្លៃភ្លាមៗ។ ការស៊ើបអង្កេត និងរបាយការណ៍សម្ងាត់នឹងត្រូវបានធ្វើឡើងដោយអនុវត្តតាមគោលការណ៍ ឬបរិបទច្បាប់ក្នុងស្រុក/ប្រទេសដែលមាន។ នាយកប្រតិបត្តិ និងប្រធានផ្នែកការពារកុមាររបស់ស៊ីស៊ីអេហ្វ ត្រូវបានកត់សំគាល់ជានិច្ច។ នាយកគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការមានទំនួលខុសត្រូវរួមសម្រាប់ការស៊ើបអង្កេត។

**៦ លទ្ធផលដែលអាចកើតមានឡើង**

ការប្រព្រឹត្តប្រាសចាកពីគោលការណ៍និងក្រមសីលធម៌ការពារកុមារអាចជាលទ្ធផលត្រូវបញ្ឈប់ពីការងារបន្ទាប់ពីការវាយតម្លៃ។

សុវត្ថិភាពរបស់ជនរងគ្រោះ និងអ្នកត្រូវបានចោទប្រកាន់ត្រូវបានវាយតម្លៃ និងឆ្លើយតប។

បញ្ហាបទឧក្រិដ្ឋ ឬរបាយការណ៍ការពារកុមារត្រូវបានបំពេញនិងបញ្ជូនទៅប៉ូលីស ឬអង្គភាពការកុមារ។

អាចទំនាក់ទំនងមកនាយកគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការ និងប្រធានផ្នែកការពារកុមារ ដើម្បីសុំការណែនាំបានគ្រប់ពេល។ មតិយោបល់និងការពិគ្រោះយោបល់សមស្រប និងត្រូវផ្ដល់ដោយផ្ទាល់តាមដែលអាចធ្វើទៅបានសំរាប់អ្នកជាប់ពាក់ព័ន្ធដើម្បីការពារឯកជនភាព និងរក្សាការសម្ងាត់។



# គោល
# នយោបាយ
# ការពារកុមារ

CAMBODIAN CHILDREN'S FUND